**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម**
**អគ្គលេខាធិការដ្ឋាន**
លេខៈ ១៥០/២៥ អឧកស.រប

*ថ្ងៃពុធ ៧រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨*
*រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៥*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីលទ្ធផលនៃសម័យប្រជុំឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លើកទី៣៨
# នៅថ្ងៃពុធ ទី១៩ ខែកុម្ភៈ ឆ្នាំ២០២៥

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានកិត្តិយសសូមជម្រាបជូនដល់អង្គចៅក្រម និងសាធារណជនជ្រាបថា **នាថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៥ វេលាម៉ោង ១០និង០០នាទីព្រឹក** ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានបើកសម័យប្រជុំលើកទី៣៨ នៅក្នុងព្រះបរមរាជវាំង ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ព្រះប្រធានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដើម្បីពិនិត្យសម្រេច និងពិគ្រោះយោបល់ លើរបៀបវារៈចំនួន១៣ ដោយទទួលបាននូវលទ្ធផលដូចខាងក្រោមៈ

**<u>របៀបវារៈទី១៖</u>** ពិនិត្យ និងសម្រេច លើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមៈ សម្រាប់សម័យប្រជុំលើកទី៣៨នេះ អង្គប្រជុំបានសម្រេចយល់ព្រមលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ពាក់ព័ន្ធនឹងករណីចៅក្រមចំនួន **១៤ករណី** និងករណីព្រះរាជអាជ្ញា ចំនួន **៩ករណី** ដែលក្នុងនោះដាក់វិន័យក្រោមរូបភាព ស្តីបន្ទោសដោយផ្ទាល់មាត់ចំនួន **៤ករណី**, ស្តីបន្ទោសដោយចុះក្នុងសំណុំលិខិតផ្ទាល់ខ្លួនចំនួន **១១ករណី**, ផ្អាកមិនឱ្យចុះឈ្មោះក្នុងតារាងដំឡើងថ្នាក់ ឬឋានន្តរស័ក្តិមួយរយៈតែមិនត្រូវឱ្យលើសពី ២ឆ្នាំទេ ឬលុបឈ្មោះចេញពីតារាងដំឡើងថ្នាក់ ឬឋានន្តរស័ក្តិវិញ ក្នុងករណីដែលបានចុះឈ្មោះរួចហើយចំនួន **៣ករណី**, ផ្លាស់ដោយបង្ខំ **១ករណី**, ផ្លាស់ដោយបង្ខំ តម្រូវឱ្យទទួលការបណ្តុះបណ្តាលបន្ថែមចំនួន **២ករណី**, ផ្លាស់ដោយបង្ខំនិងទម្លាក់ឋានៈ **១ករណី** និងព្យួរពីការងារមិនឱ្យមានបៀវត្សក្នុងរយៈពេល ៦ខែ **១ករណី**។

ជាមួយគ្នានេះ, ក្នុងចន្លោះសម័យប្រជុំលើកទី៣៧ និងលើកទី៣៨, ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក៏បានពិនិត្យ និងសម្រេច លើវិន័យការងារចំពោះករណីព្រះរាជអាជ្ញារង **១នាក់** ដោយសម្រេចដាក់វិន័យក្រោមរូបភាព បណ្តេញចេញពីក្របខណ្ឌព្រះរាជអាជ្ញា ផងដែរ។

**<u>របៀបវារៈទី២៖</u>** ពិនិត្យ និងសម្រេច អំពីការផ្ទេរ និងតែងតាំង ចៅក្រម មួយចំនួនៈ អង្គប្រជុំបានសម្រេចយល់ព្រមលើការស្នើផ្ទេរភារកិច្ច និងតែងតាំងមុខតំណែង ប្រធាន អនុប្រធាន និងចៅក្រម នៃសាលាជម្រះក្តីមួយចំនួន ដែលដល់វេនត្រូវធ្វើការផ្លាស់ប្តូរ និងដោយយោងទៅតាមតម្រូវការជាក់ស្តែង ក្នុងនោះរួមមាន ថ្នាក់តុលាការកំពូលចំនួន **៥នាក់**, ថ្នាក់សាលាឧទ្ធរណ៍ចំនួន **១២នាក់** និងថ្នាក់សាលាដំបូងរាជធានី-ខេត្ត ចំនួន **៥៦នាក់**។



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម E-mail: info@scm.gov.kh ទូរស័ព្ទ : 855-23-726 150

**<u>របៀបវារៈទី៣៖</u>** ពិគ្រោះយោបល់ លើសំណើផ្ទេរ និងតែងតាំង ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង មួយចំនួន តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌៖ អង្គប្រជុំបានផ្តល់យោបល់យល់ព្រមលើសំណើផ្ទេរភារកិច្ច និងតែងតាំងមុខតំណែង ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង នៅថ្នាក់មហាអយ្យការអមតុលាការកំពូល **១នាក់**, ថ្នាក់មហាអយ្យការអមសាលាឧទ្ធរណ៍ចំនួន **២នាក់** និងនៅថ្នាក់អយ្យការអមសាលាដំបូងរាជធានី-ខេត្តចំនួន **២១នាក់**។

**<u>របៀបវារៈទី៤-</u>**ពិនិត្យ និងសម្រេច អំពីការកែសម្រួល និងតែងតាំង សមាសភាពនៃក្រុមអធិការកិច្ចនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម៖ អង្គប្រជុំបានសម្រេចយល់ព្រមធ្វើការកែសម្រួល និងតែងតាំងសមាសភាពក្រុមអធិការកិច្ចនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលមានសមាសភាពសរុបចំនួន **២០នាក់**។

**<u>របៀបវារៈទី៥-</u>**ពិនិត្យ និងផ្តល់យោបល់ អំពីការស្នើដំឡើងថ្នាក់ ឋានន្តរស័ក្តិ តាមវេនអតីតភាព តាមកម្រិតសញ្ញាបត្រ ចំពោះចៅក្រម និងព្រះរាជអាជ្ញា៖ សម្រាប់សម័យប្រជុំលើកទី៣៨ នេះ អង្គប្រជុំបានផ្តល់យោបល់យល់ព្រម ចំពោះសំណើសុំដំឡើងថ្នាក់ ឋានន្តរស័ក្តិតាមវេនអតីតភាព តាមកម្រិតសញ្ញាបត្រ ចំពោះចៅក្រម និងព្រះរាជអាជ្ញា សរុបទាំងអស់មានចំនួន **៣៧៨នាក់** ក្នុងនោះចំនួន **៣១២នាក់** ត្រូវស្នើតាមវេនអតីតភាព និងចំនួន **៦៦នាក់** ត្រូវស្នើតាមកម្រិតសញ្ញាបត្រ។

**<u>របៀបវារៈទី៦-</u>**ពិនិត្យ និងសម្រេច អំពីសំណើសុំតាំងស៊ប់ក្នុងក្របខណ្ឌចៅក្រម ចំពោះចៅក្រមកម្មសិក្សាចំនួន ៣៥នាក់៖ សម្រាប់សម័យប្រជុំលើកនេះ អង្គប្រជុំបានអនុម័តយល់ព្រមតាំងស៊ប់ក្នុងក្របខណ្ឌចៅក្រម ចំពោះចៅក្រមកម្មសិក្សា ចំនួន **៣៥នាក់** និងចាត់ឱ្យទៅបំពេញការងារនៅសាលាដំបូងខេត្ត។

**<u>របៀបវារៈទី៧-</u>**ពិគ្រោះយោបល់ លើសំណើសុំតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញា ចំពោះព្រះរាជអាជ្ញារងកម្មសិក្សា ចំនួន ២០នាក់ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌៖ អង្គប្រជុំបានផ្តល់យោបល់យល់ព្រមលើសំណើសុំតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញា ចំពោះព្រះរាជអាជ្ញារងកម្មសិក្សា ចំនួន **២០នាក់** និងចាត់ឱ្យទៅបំពេញការងារនៅអយ្យការអមសាលាដំបូងខេត្ត តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**<u>របៀបវារៈទី៨-</u>**ពិនិត្យ និងសម្រេច អំពីសំណើសុំចូលបម្រើការងារវិញ របស់លោកជំទាវ **ខៀវ សុខា** អតីតអនុប្រធានសាលាឧទ្ធរណ៍ភ្នំពេញ៖ សម្រាប់សម័យប្រជុំលើកនេះ អង្គប្រជុំបានអនុម័តយល់ព្រមអនុញ្ញាតឱ្យលោកជំទាវ **ខៀវ សុខា** អតីតអនុប្រធានសាលាឧទ្ធរណ៍ភ្នំពេញ ចូលបម្រើការងារជាចៅក្រមនៅអង្គភាពវិញ និងតែងតាំងជាអនុប្រធានសាលាឧទ្ធរណ៍ភ្នំពេញ។

**<u>របៀបវារៈទី៩-</u>**ពិគ្រោះយោបល់ លើសំណើសុំដាក់ឱ្យនៅទំនេរគ្មានបៀវត្សរយៈពេល ២ឆ្នាំ របស់ព្រះរាជអាជ្ញារង ចំនួន ២នាក់៖ សម្រាប់សម័យប្រជុំលើកនេះ អង្គប្រជុំបានផ្តល់យោបល់យល់ព្រមលើសំណើសុំរបស់ព្រះរាជអាជ្ញារងទាំង **២នាក់** ដូចតទៅ៖

ទី១-អនុញ្ញាតឱ្យលោកស្រី **ឆេង ហាក់ងិង** ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តសៀមរាប ឈប់សម្រាកដោយគ្មានបៀវត្សរយៈពេល ២ឆ្នាំ គិតចាប់ពីថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៤ ដល់ថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៦។

ទី២-អនុញ្ញាតឱ្យលោក **សាយ ណូរ៉ា** ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង ឈប់សម្រាកដោយគ្មានបៀវត្សរយៈពេល ២ឆ្នាំ គិតចាប់ពីថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៥ ដល់ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៧។

TR

**<u>របៀបវារៈទី១០</u>**-ពិនិត្យ និងសម្រេច អំពីសំណើសុំអនុញ្ញាតច្បាប់ទៅបន្តការសិក្សា របស់ចៅក្រម ១នាក់ នៃសាលាដំបូងខេត្តកណ្ដាល៖ អង្គប្រជុំបានអនុម័តយល់ព្រមអនុញ្ញាតច្បាប់ឈប់សម្រាកពីការងារបន្ថែមចំនួន ១ឆ្នាំទៀត ដល់លោកស្រី **អ៊ី ម៉ាណូកា** ចៅក្រមសាលាដំបូងខេត្តកណ្ដាល គិតចាប់ពីថ្ងៃទី៣ ខែសីហា ឆ្នាំ២០២៤ ដល់ថ្ងៃទី៣ ខែសីហា ឆ្នាំ២០២៥ ដោយរក្សាក្របខណ្ឌ និងគ្មានប្រាក់បៀវត្ស។

**<u>របៀបវារៈទី១១</u>**-ពិនិត្យ និងសម្រេច អំពីសំណើសុំអនុញ្ញាតច្បាប់ទៅបន្តការសិក្សា របស់ចៅក្រម ១នាក់ នៃសាលាដំបូងខេត្តពោធិ៍សាត់៖ អង្គប្រជុំបានអនុម័តយល់ព្រមអនុញ្ញាតឱ្យលោកស្រី **សាមឆាយ លីនណា** ចៅក្រមសាលាដំបូងខេត្តពោធិ៍សាត់ បានឈប់សម្រាកពីការងារ ដោយរក្សាក្របខណ្ឌ និងប្រាក់បៀវត្ស រយៈពេល ១ឆ្នាំ គិតចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៥ ដល់ថ្ងៃទី១ ខែមករា ឆ្នាំ២០២៦។

**<u>របៀបវារៈទី១២</u>**-ពិគ្រោះយោបល់ អំពីការស្នើសុំបំពេញកម្មសិក្សាការងារ ជាព្រះរាជអាជ្ញារងកម្មសិក្សា សម្រាប់សិស្សចៅក្រមផ្ទៃក្នុង ជំនាន់ទី២ នៃបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា៖ សម្រាប់សម័យប្រជុំលើកនេះ អង្គប្រជុំបានផ្ដល់យោបល់យល់ព្រមលើការស្នើសុំបំពេញកម្មសិក្សាការងារ ជាព្រះរាជអាជ្ញារងកម្មសិក្សា សម្រាប់សិស្សចៅក្រមផ្ទៃក្នុង ជំនាន់ទី២ ចំនួន **១៥នាក់** នៃបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា។

**<u>របៀបវារៈទី១៣</u>**-បញ្ហាផ្សេងៗ៖ ចំពោះរបៀបវារៈនេះ អង្គប្រជុំមិនមានបញ្ហាអ្វីលើកឡើងទេ។

ជាទីបញ្ចប់នៃកិច្ចប្រជុំ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ព្រះប្រធានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត បានថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះការខិតខំយកចិត្តទុកដាក់បំពេញការងារ របស់សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ **ព្រះករុណាព្រះប្រធាន** ព្រះអង្គបានប្រកាសបិទសម័យប្រជុំលើកទី៣៨ របស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ប្រកបដោយជោគជ័យ និងបរិយាកាសល្អប្រសើរ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង ១១និង៥៥នាទី នាថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៥។

*អាស្រ័យដូចបានជម្រាបជូនខាងលើ សូមអង្គចៅក្រម និងសាធារណជន មេត្តាជ្រាបជាព័ត៌មាន។*

**អគ្គលេខាធិការ**

**សំ ប្រជាមានិត**